ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.............................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ថ្លែងក្នុងឱកាសបើកវគ្គបណ្តុះបណ្តាលបាគខ២ ស្តីពី "ការត្រួតពិនិត្យធនាគារ"

នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣

សូមគោរព :

- លោក Faisal Ahmed តំណាងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា
- លោក Arnaud de Villepoix ជំនាញការទូទៅរបស់ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋាន ស្តីពីការត្រួតពិនិត្យធនាគារ ។ នេះ ជាលើកទី២ហើយដែលធនាគារជាតិនៃកម្ពុជាយើងបានរៀបចំវគ្គនេះឡើងដោយខ្លួនឯង សម្រាប់បណ្តុះបណ្តាលមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា អំពីចំណេះដឹងមូលដ្ឋាន និងជំនាញការងារទាក់ទងនឹងការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ វគ្គនេះ គឺជាយន្តការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកនៅនឹងកន្លែង ដែលធនាគារជាតិនៃកម្ពុជាយើងរៀបចំឡើងក្រោមរូបភាពជា In-house Training ដោយប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន ទាំងផ្នែកបញ្ញាញាណ និងផ្នែកសម្ភារៈ ក្នុងគោលបំណងដើម្បីចែករំលែកព័ត៌មាននិងផ្ទេរចំណេះដឹង ចំណេះធ្វើ បទពិសោធន៍និងជំនាញឯកទេសពីវិធីសាស្ត្រអនុវត្តការងារជាក់ស្តែង ជូនមន្ត្រីបុគ្គលិកជំនាន់ក្រោយ ដែលជាអ្នកបន្តវេននិងបន្តនិរន្តរភាពការងាររបស់យើង ឆ្ពោះទៅរកការអភិវឌ្ឍប្រព័ន្ធធនាគារ ប្រកបដោយប្រសិទ្ធភាព ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក្នុងក្របខ័ណ្ឌនៃសមាហរណកម្មសេដ្ឋកិច្ច និងសេរីភាវូបនីយកម្មសេដ្ឋកិច្ច នៅក្នុងតំបន់ និងពិភពលោកនាពេលបច្ចុប្បន្ន ។

វគ្គនេះ គឺជាថ្នាលបណ្តុះបណ្តាលមួយយ៉ាងសំខាន់ សម្រាប់មន្ត្រីបុគ្គលិកយើងដែលទទួលបន្ទុកការងារត្រួតពិនិត្យធនាគារ បានផ្លាស់ប្តូរយោបល់និងសិក្សាស្វែងយល់ពីចំណេះដឹងមូលដ្ឋាន ទាក់ទងនឹងក្របខ័ណ្ឌច្បាប់អនុវត្តក្នុងវិស័យធនាគារ មុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែល ស្តីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព និងវិធីសាស្ត្រផ្សេងៗទៀតដែលទាក់ទងនឹងការត្រួតពិនិត្យនិងបញ្ញត្តិកម្មជាដើម ។



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឯកឧត្តម លោកជំទាវ លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី !

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា កាលពីឆ្នាំមុនខ្ញុំបានប្រសិទ្ធនាមវគ្គបណ្តុះ-បណ្តាលនេះថា "វគ្គបាគង១" ហើយគោលបំណងដែលខ្ញុំលើកយកពាក្យ "បាគង" មកប្រើពេលនោះ គឺសំដៅដល់ ៖

១/. ឈ្មោះប្រាសាទបុរាណខ្មែរមួយ ហៅថា "ប្រាសាទបាគង" ដែលមានទីតាំងស្ថិតនៅរលួស ខេត្តសៀមរាប ត្រូវបានកសាងឡើងនៅឆ្នាំ៨៨១ ដោយព្រះបាទឥន្ទ្រវរ្ម័នទី១ *(ព្រះឥន្ទ្រ មានន័យថាជាអ្នកការពារ)* សម្រាប់ឧទ្ទិសដល់ព្រះសិវៈ ។ ប្រាសាទបាគង ជាប្រាសាទភ្នំ តំណាងភ្នំមេរុ ដោយសារមានកំពែងនិងគូទឹកព័ទ្ធជុំវិញ ស្ថិតនៅចំកណ្តាលនៃក្រុងហរិហរាល័យដែលព្រះបាទជ័យវរ្ម័នទី៣បានបង្កើតឡើងនៅដើមសតវត្សរ៍ទី៩ ។

២/. និមិត្តរូបនៃប្រាសាទបាគងដែលបានកសាងឡើង ដើម្បីបង្ហាញពីការខិតខំតស៊ូអភិវឌ្ឍជាតិឱ្យរីកចម្រើនរុងរឿងដោយខ្មែរខ្លួនឯង នៅមុនសម័យអង្គរ ។ ជាក់ស្តែងវិមានឯករាជ្យនៅរាជធានីភ្នំពេញបច្ចុប្បន្ន ត្រូវបានកសាងឡើងតាមរចនាបទប្រាសាទបាគងបន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យជាតិពីអាណានិគមបារាំងនៅឆ្នាំ១៩៥៣ ដើម្បីបង្ហាញពីគំរូវីរភាពនៃការតស៊ូរបស់ប្រជាជនកម្ពុជា ដើម្បីបុព្វហេតុឯករាជ្យជាតិ កសាងអធិបតេយ្យភាព បូរណភាពដែនដី សុខសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដោយខ្លួនឯងផងដែរ និង

៣/. ភាពម្ចាស់ការរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងខិតខំរៀបចំបណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្សដោយខ្លួនឯង សម្រាប់អភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យកាន់តែរីកចម្រើន និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់និងពិភពលោកថែមទៀត ។

ធនធានមនុស្ស គឺជាគន្លឹះសម្រាប់នាំមកនូវភាពជោគជ័យជូនស្ថាប័ននិងប្រទេសជាតិ ។ ការអភិវឌ្ឍធនធានមនុស្ស ចាំបាច់ត្រូវធ្វើជាប់ជាប្រចាំ ដើម្បីបន្តនិរន្តភាពការងារ និងនាំមកនូវភាពជោគជ័យថ្មីៗទៀតជូនធនាគារជាតិនៃកម្ពុជាយើង ។ ខណៈដែលប្រព័ន្ធធនាគារនៅកម្ពុជា បាននិងកំពុងអភិវឌ្ឍរីកចម្រើនជាង២ទសវត្សរ៍កន្លងមក យើងបានខិតខំពង្រឹងប្រតិបត្តិការធនាគារកណ្តាល តាមរយៈការកែសម្រួលរចនាសម្ពន្ធចាត់តាំងផ្ទៃក្នុង ឱ្យស្របតាមតម្រូវការការងារចាំបាច់នៃស្ថានភាពរីកចម្រើនរបស់ប្រព័ន្ធធនាគារ ។ ជាមួយគ្នានេះយើងក៏បានខិតខំបណ្តុះបណ្តាលមន្ត្រីលើផ្នែកជំនាញឯកទេសកម្ម ទាំងក្នុងនិងក្រៅប្រទេសជាពិសេស គឺការងារត្រួតពិនិត្យធនាគាររហូតមកដល់បច្ចុប្បន្ននេះ ។

នៅពេលដែលយើងពង្រឹងសមត្ថភាពគ្រប់គ្រងខ្លួនឯងបានរឹងមាំរួចហើយ ទើបធនាគារជាតិនៃកម្ពុជាយើងចាប់ផ្តើមពង្រឹងប្រព័ន្ធធនាគារតាមក្រោយ ។ ជាក់ស្តែង បន្ទាប់ពីច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានអនុម័តនៅឆ្នាំ១៩៩៩ សម្រាប់ធ្វើជាមូលដ្ឋានគតិយុត្តិ ដើម្បីគ្រប់គ្រងប្រតិបត្តិការធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរអាណាព្យាបាលត្រួតពិនិត្យ បានធ្វើកំណែទម្រង់ប្រព័ន្ធធនាគារនៅកម្ពុជា ដោយការផ្តល់អាជ្ញាប័ណ្ណជាថ្មី និងបានពង្រឹងសុខភាពប្រព័ន្ធធនាគារ តាមរយៈយន្តការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង ព្រោះភាពរឹងមាំនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺជាការការពារប្រភពទុនប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

ដើម្បីអនុវត្តភារកិច្ចនេះឱ្យមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបន្តខិតខំកសាងនិងពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករ ឱ្យដើរទាន់សភាពការជាប្រែប្រួលនៃអភិក្រមអន្តរជាតិ និងធានាបាននូវសវុត្ថិភាពប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព ។ វិធានការដែលយើងបានអនុវត្តសម្រាប់សម្រិតសម្រាំងមន្ត្រីបុគ្គលិកកន្លងមក រួមមាន ៖

១/. ចាប់តាំងពីឆ្នាំ១៩៩៩មក យើងបានអនុវត្តនយោបាយប្រឡងជ្រើសរើសដោយហ្មត់ចត់ នូវមន្ត្រីដែលមានសមត្ថភាពនិងចំណេះដឹងមូលដ្ឋានផ្នែកសេដ្ឋកិច្ច ធនាគារនិងហិរញ្ញវត្ថុ គណនេយ្យ និងភាសាអង់គ្លេស ។

២/. បន្ទាប់មក យើងបានបណ្តុះបណ្តាលមន្ត្រីចូលថ្មីទាំងនោះតាំងពីដំបូងទី ។ ដោយមានជំនួយបច្ចេកទេសពី IMF យើងបានរៀបចំឱ្យមានការបណ្តុះបណ្តាលជាច្រើនរូបភាព គ្រាន់តែនៅមិនទាន់បានរៀបចំឱ្យមានលក្ខណៈជាខ្សែចង្វាក់នៅឡើយ ។

៣/. ក្រៅពីនោះ យើងក៏បានបញ្ជូនមន្ត្រីយើងទៅបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេស ក្រោមរូបភាពជាការចូលរួមសិក្ខាសាលា ឬ វគ្គបណ្តុះបណ្តាលនៅបណ្តាធនាគារកណ្តាលនិងអង្គការអន្តរជាតិ ក្នុងតំបន់និងពិភពលោក ជាបន្តបន្ទាប់ផងដែរ ។

៤/. ធនាគារជាតិនៃកម្ពុជា ក៏បានលើកទឹកចិត្តឱ្យមន្ត្រីយើងបង្កើនសមត្ថភាពរបស់ខ្លួនតាមរយៈការងារផង និងរៀនផង ជាប្រចាំ ។

ប៉ុន្តែ ទោះបីជាយើងបានខិតខំ និងបានទទួលលទ្ធផលជាហូរហែកន្លងមកក៏ដោយក៏យើងនៅតែទទួលស្គាល់ថា ប្រភពបណ្តុះបណ្តាលខាងលើនេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ បើប្រៀបធៀបនឹងទំហំការងារជាក់ស្តែងរបស់យើងបច្ចុប្បន្ន ដែលចេះតែរីកធំពីមួយថ្ងៃទៅមួយថ្ងៃ ។ នៅចុងឆ្នាំ២០១០ ដោយការងាររបស់យើងបានរីកចម្រើនទាំងផ្នែកវិសាលភាពនិងទំហំសកម្មភាព នាយកដ្ឋានត្រួតពិនិត្យ ត្រូវបានកែសម្រួលឱ្យ

ទៅជា "អគ្គនាយកដ្ឋានត្រួតពិនិត្យ" ដោយមាននាយកដ្ឋានចំនួន៤នៅក្រោមឱវាទ ស្របតាមស្ថានភាពអភិវឌ្ឍរីកចម្រើននៃប្រព័ន្ធធនាគារនៅកម្ពុជា ។ បច្ចុប្បន្ន អគ្គនាយកដ្ឋាននេះ មានមន្ត្រីបុគ្គលិកសរុប ចំនួន៩៣រូប ក្នុងនោះបុគ្គលិកទើបចូលថ្មីកាលពីចុងឆ្នាំ២០១២ ចំនួន១៣រូប ដែលចំណេះដឹងនិងបទពិសោធន៍មានកម្រិតខុសៗគ្នា ។ មន្ត្រីចាស់ ដែលបានចូលបម្រើការងារមុន មានបទពិសោធន៍ច្រើនជាង បានទទួលការបណ្តុះបណ្តាលច្រើនទាំងក្នុងនិងក្រៅប្រទេស ។ មន្ត្រីទើបនឹងចូលថ្មី មានបទពិសោធន៍តិចជាង ឯការបណ្តុះ-បណ្តាលក៏នៅតិចដែរ ។ ដូច្នេះការបណ្តុះបណ្តាលរបស់យើងត្រូវធ្វើទាំងផ្នែកទ្រឹស្តី ចំណេះដឹងបច្ចេកទេស គុណធម៌ សីលធម៌ និងវិន័យការងារបន្ថែមទៀត ។ បើពុំដូច្នេះទេ យើងពុំអាច ដើរទាន់សភាពការណ៍អភិវឌ្ឍរីកចម្រើននៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៃប្រទេសក្នុងតំបន់និងពិភពលោក ដែលមានលក្ខណៈសមាហរណកម្មនិងប្រទាក់ក្រឡាគ្នាដូចពេលបច្ចុប្បន្ននេះឡើយ ។

ដូច្នេះ ការបើកវគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យធនាគារ" នាថ្ងៃនេះ ដើម្បីផ្តល់នូវចំណេះដឹងជាមូលដ្ឋានដល់មន្ត្រីត្រួតពិនិត្យរបស់យើង គឺដើម្បីឆ្លើយតបនិងតម្រូវការការងាររបស់យើងនាពេលបច្ចុប្បន្នផង និងទៅអនាគតផង ។ កាលណាមានចំណេះដឹងជាមូលដ្ឋានហើយ មន្ត្រីយើងនឹងមានសមត្ថភាពស្រូបយកចំណេះដឹងនិងបទពិសោធន៍ក្នុងការត្រួតពិនិត្យនេះឱ្យកាន់តែស៊ីជម្រៅថែមទៀត ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាមជាទីមេត្រី !**

ដើម្បីជ្រាបពីប្រវត្តិនៃការប្រែប្រួលនៃតួនាទីធនាគារកណ្តាល និងសារៈសំខាន់នៃការត្រួតពិនិត្យប្រព័ន្ធធនាគារ ខ្ញុំសូមលើកយកទស្សនាទានសំខាន់ៗ ចំនួន ២ ចំណុច ដូចតទៅ ៖

*ក/. ប្រវត្តិនៃការបង្កើតធនាគារកណ្តាល* ៖ ដំបូងត្រូវបានបង្កើតឡើងនៅប្រទេសស៊ុយអែត ក្នុងឆ្នាំ១៦៦៨ និងនៅប្រទេសអង់គ្លេស នៅឆ្នាំ១៦៩៥ សម្រាប់ផ្តល់ប្រាក់ឱ្យរដ្ឋាភិបាលខ្ចី។ បន្ទាប់មក នៅសតវត្សរ៍ទី១៩ ប្រទេសជាច្រើននៅអឺរ៉ុបក៏បានបង្កើតធនាគារកណ្តាលរៀងៗខ្លួនផងដែរ ដើម្បីបំពេញតួនាទីជាធនាគារិករបស់រដ្ឋ និងមានកាតព្វកិច្ចជាពិសេស ក្នុងការផ្តល់ហិរញ្ញប្បទានធ្វើសង្គ្រាមនិងប៉ះប៉ូវឱនភាពថវិការដ្ឋ ។ ដូច្នេះ ទើបធនាគារកណ្តាលបានទទួលបុព្វសិទ្ធិដ៏ពិសេសផ្តាច់មុខពីរដ្ឋ ក្នុងការបោះពុម្ពនិងបោះផ្សាយនូវធនបត្រ ដែលភាសាសាមញ្ញយើងហៅថា "បោះពុម្ពក្រដាសប្រាក់" ។ តួនាទីនិងភារកិច្ចរបស់ធនាគារកណ្តាលទាំងនោះ តែងតែប្រែប្រួលជាប់ជាប្រចាំទៅតាមការវិវត្តនៃពេលវេលានិងការរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។